ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ១៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរធនធានបន្ថែមពីថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១._**

អនុក្រឹត្យនេះ កំណត់អំពីទំហំ ការផ្ទេរ និងការគ្រប់គ្រងធនធានបន្ថែមពីថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ក្នុងចិរវេលា ០៥(ប្រាំ)ឆ្នាំ ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨ ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍនៅមូលដ្ឋាន។

**មាត្រា២._**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើរដ្ឋបាលឃុំ សង្កាត់ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែរដ្ឋបាលសង្កាត់ចំណុះរាជធានីភ្នំពេញ។

## ជំពូកទី២
## ប្រភពធនធាន

**មាត្រា៣._**

កម្រិតនៃការផ្ទេរធនធានបន្ថែមពីថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ក្នុងថិរវេលា ០៥(ប្រាំ)ឆ្នាំ ត្រូវបានកំណត់ជាភាគរយ ដូចខាងក្រោម÷

- ឆ្នាំថវិកា២០២៤ : ចំនួន ១ភាគរយនៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដែលបានអនុម័តឆ្នាំ២០២៣
- ឆ្នាំថវិកា២០២៥ : ចំនួន ១ភាគរយនៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដែលបានអនុម័តឆ្នាំ២០២៤
- ឆ្នាំថវិកា២០២៦ : ចំនួន ១ភាគរយនៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដែលបានអនុម័តឆ្នាំ២០២៥
- ឆ្នាំថវិកា២០២៧ : ចំនួន ១ភាគរយនៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដែលបានអនុម័តឆ្នាំ២០២៦
- ឆ្នាំថវិកា២០២៨ : ចំនួន ១ភាគរយនៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដែលបានអនុម័តឆ្នាំ២០២៧។

## ជំពូកទី៣
## ការគ្រប់គ្រង ការបែងចែក ការផ្ទេរ
## និងការប្រើប្រាស់ធនធានបន្ថែមពីថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់

**មាត្រា៤._**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គ្រប់គ្រងធនធានបន្ថែមពីថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ដែលកំណត់ក្នុងអនុក្រឹត្យនេះ ព្រមទាំងមានភារកិច្ចដូចខាងក្រោម÷

- រៀបចំវិភាជន៍ជូនរដ្ឋបាលឃុំ សង្កាត់នីមួយៗ
- ជូនដំណឹងជាផ្លូវការដល់រដ្ឋបាលឃុំ សង្កាត់នីមួយៗ អំពីទំហំធនធាន ដែលត្រូវទទួលបានពីការវិភាជសម្រាប់ឆ្នាំថវិកាបន្ទាប់នៅមុនដំណាច់ខែមិថុនានៃឆ្នាំថវិកា
- បញ្ជាការផ្ទេរធនធានបន្ថែមនេះទៅគណនីប្រាក់បញ្ញើរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗ
- ត្រួតពិនិត្យ និងតាមដានការផ្ទេរធនធានបន្ថែមនេះ។

**មាត្រា៥._**

ធនធានបន្ថែមពីថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ត្រូវបានវិភាជ ទៅឱ្យរដ្ឋបាលឃុំ សង្កាត់នីមួយៗតាមការគណនាដោយផ្អែកលើរូបមន្ត និងសន្ទស្សន៍ដូចខាងក្រោម÷

- ចំនួន ៣០ភាគរយ ជាចំណែកស្មើគ្នាត្រូវបានបែងចែកក្នុងចំនួនស្មើៗគ្នា សម្រាប់រដ្ឋបាលឃុំ សង្កាត់នីមួយៗ

- ចំនួន ៣០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនប្រជាពលរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ
- ចំនួន ៣០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃសន្ទស្សន៍ភាពក្រីក្រដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ និង
- ចំនួន ១០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនភូមិរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងមហាផ្ទៃ។

**មាត្រា៦._**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបោះផ្សាយអាណត្តិឧបត្ថម្ភធនជូនរដ្ឋបាលឃុំ សង្កាត់សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន និងផ្ទេរដោយត្រង់ចូលគណនីប្រាក់បញ្ញើរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗជា ០៤(បួន)លើក សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំតាមកម្មវិធីដូចខាងក្រោម÷

- លើកទី១ : ផ្ទេរ ២៥ភាគរយនៃធនធានវិភាជន៍សរុបនៅដើមត្រីមាសទី១
- លើកទី២ : ផ្ទេរ ២៥ភាគរយនៃធនធានវិភាជន៍សរុបនៅដើមត្រីមាសទី២
- លើកទី៣ : ផ្ទេរ ២៥ភាគរយនៃធនធានវិភាជន៍សរុបនៅដើមត្រីមាសទី៣
- លើកទី៤ : ផ្ទេរ ២៥ភាគរយនៃធនធានវិភាជន៍សរុបនៅដើមត្រីមាសទី៤។

**មាត្រា៧._**

រដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវគ្រោង និងប្រើប្រាស់ធនធានបន្ថែមពីថវិការដ្ឋ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាននេះក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំ ដូចគ្នាទៅនឹងការគ្រោង និងការប្រើប្រាស់ធនធានសមាសភាគអភិវឌ្ឍន៍មូលដ្ឋាននៃមូលនិធិឃុំ សង្កាត់ស្របតាមច្បាប់ និងបទប្បញ្ញត្តិដែលមានការពាក់ព័ន្ធជាធរមាន។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា៨._**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ក្រុមប្រឹក្សារាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក អភិបាលនៃគណៈអភិបាលក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃចន្ទ ៨ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ